ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប
ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)
**លេខាធិការដ្ឋាន**

លេខៈ ...០៤៩៧... /គ.ជ.អ.ប

រាជធានីភ្នំពេញ, ថ្ងៃទី...១៧... ខែ...ឧសភា... ឆ្នាំ២០១៦

**សូមគោរពជូន**

**សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.អ.ប**

**កម្មវត្ថុ÷** សំណើសុំគោលការណ៍អនុវត្តកម្មវិធី "កំណែទម្រង់វិមជ្ឈការ និងរដ្ឋបាល" (Decentralization and Administrative Program ហៅកាត់ថាDAR)។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទសូមគោរពជម្រាបជូន **សម្តេចក្រឡាហោម** មេត្តាជ្រាបថា ផ្អែកលើលទ្ធផលនៃការចរចាស្តីពីកិច្ចសហប្រតិបត្តការទ្វេភាគីរវាងរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលអាឡឺម៉ង់ កាលពីចុងឆ្នាំ២០១៥ រដ្ឋាភិបាលអាឡឺម៉ង់បានសម្រេចផ្តល់ហិរញ្ញប្បទាន**ចំនួន៣.៣០០.០០០EUR (បីលានបីសែនអឺរ៉ូ)** ដើម្បីបន្តគាំទ្រដល់កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និងកំណែទម្រង់រដ្ឋបាលសាធារណៈរបស់កម្ពុជា។ ថវិកានេះនឹងគ្រប់គ្រង ចាត់ចែងដោយអង្គការ GIZ តាមរយៈកម្មវិធីដែលមានឈ្មោះថា "កំណែទម្រង់វិមជ្ឈការ និងរដ្ឋបាល" ដែលមានគោលដៅជួយលើកកម្ពស់ការផ្តល់សេវាសាធារណៈរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ កម្មវិធីនេះបានជ្រើសរើសយកខេត្តគោលដៅចំនួន២ និងស្រុកចំនួន៦រួមមាន៖ ខេត្តបាត់ដំបងមាន៣ស្រុកគឺ ស្រុកមោងឫស្សី ស្រុកបាណន់ និងស្រុកគាស់ក្រឡ និងខេត្តកណ្តាលមាន៣ស្រុកគឺ ស្រុកលើកដែក ស្រុកស្អាង និងស្រុកគៀនស្វាយ។ កម្មវិធីនេះអនុវត្តក្នុងរយៈពេល៣២ខែ **ដែលចាប់ពីខែមិថុនា ឆ្នាំ២០១៦ ដល់ខែធ្នូ ឆ្នាំ២០១៨**។

ជារួម លេខាធិការដ្ឋាន គ.ជ.អ.ប យល់ឃើញថា គម្រោងនេះពិតជាមានសារៈសំខាន់ក្នុងការចូលរួមចំណែកគាំទ្រដល់កិច្ចដំណើរការកំណែទម្រង់របស់យើងទាំង២។ ក្នុងន័យនេះ លេខាធិការដ្ឋាន គ.ជ.អ.ប សូមគោរពស្នើសុំ **សម្តេចក្រឡាហោម** មេត្តាផ្តល់នូវការអនុញ្ញាតជាគោលការណ៍ឱ្យលេខាធិការដ្ឋានគ.ជ.អ.ប រួមជាមួយក្រសួងមុខងារសាធារណៈ និងរដ្ឋបាលខេត្ត ស្រុកគោលដៅខាងលើ សហការជាមួយ អង្គការGIZ ដើម្បីអនុវត្តកម្មវិធីនេះ ដោយរៀបចំគណៈកម្មការគ្រប់គ្រងកម្មវិធីកម្រិតនយោបាយ (Political Steering Committee) ដែលមានរូបខ្ញុំបាទជាប្រធាន និងគណៈកម្មការអនុវត្តកម្មវិធី (Opperational Steering Committee)ដែលរៀបចំនៅស្ថាប័នអនុវត្តទាំង៤ ពោលគឺលេខាធិការដ្ឋាន គ.ជ.អ.ប ក្រសួងមុខងារសាធារណៈ និងខេត្តគោលដៅទាំង២។

អាស្រ័យដូចបានគោរពជម្រាបជូនខាងលើ សូម **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** មេត្តាពិនិត្យ និងសម្រេចដ៏ខ្ពង់ខ្ពស់។

សូម **សម្តេចក្រឡាហោម** មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ។

**ប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប**